អាយុ៦-៨ឆ្នាំ

# ព្រះគម្ពីរសម្រាប់កុមារ មើលតាមរូបភាព

សញ្ញាចាស់៣

## សៀវភៅអនុវត្ត



KIDS WORSHIP GOD
www.kidsworship.kr
Selah
Ministry of Christian Publishing

# ព្រះគម្ពីរសម្រាប់កុមារមើលតាមរូបភាព

## សៀវភៅអនុវត្ត សញ្ញាចាស់៣

### អាយុ៦-៨ឆ្នាំ

កែសម្រួល kidsworship Selah

បកប្រែដោយ | KOMA Cambodia រចនាក្រាហ្វិក | Jeewon Park, Julio Blas ការកែសម្រួល | KOMA Cambodia

ហាមថតចម្លងទាំងស្រុង ឬផ្នែកណាមួយនៃសៀវភៅនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ

# លិបិក្រម




១. នាងហាណា និងសាំយូអែល ---- 6

២. ដាវីឌ និងកូលីយ៉ាត ---- 10

៣. ដាវីឌ និងយ៉ូណាថាន ---- 15

៤. សាឡូម៉ូន ---- 20

៥. អេលីយ៉ា ---- 24

៦. លោកមេទ័ពណាម៉ាន់ ---- 28

៧. ព្រះនាងអេសធើរ ---- 32

៨. យ៉ូប ---- 36

៩.ដានីយ៉ែល ---- 40

១០. យ៉ូណាស ---- 43

# ចូរកត់ត្រាអំពីដំណើរនៃសកម្មភាព។

ចូរផាត់ពណ៌ បន្ទាប់ពីបញ្ចប់រឿងនីមួយៗ។

ស្កេន QR
ដើម្បីចូលទៅស្ដាប់រឿង។



## រឿងទី១៖ នាងហាណា និងសាំយូអែល

**ខគម្ពីរ៖ ១សាំយូអែល១៖១១**

នាងទូលអង្វរព្រះអង្គ ដោយសច្ចាថា៖ «ឱ! ព្រះអម្ចាស់ នៃពិភពទាំងមូលអើយ! សូមទតមកខ្ញុំម្ចាស់ ដែលកំពុងតែមានទុក្ខព្រួយ សូមនឹកដល់ខ្ញុំម្ចាស់ ហើយកុំបំភ្លេចខ្ញុំម្ចាស់ឡើយ។ ប្រសិនបើព្រះអង្គប្រោសប្រទានឲ្យខ្ញុំម្ចាស់មានកូនប្រុសមួយ ខ្ញុំម្ចាស់នឹងយកកូននោះមកថ្វាយព្រះអង្គ ដើម្បីឲ្យនៅបម្រើព្រះអង្គអស់មួយជីវិត ហើយសក់របស់វានឹងមិនត្រូវកោរ ឬកាត់ឡើយ»។

មានបុរសម្នាក់ឈ្មោះអែលកាណា រស់នៅក្នុងស្រុកអ៊ីស្រាអែល។ អែលកាណា គាត់មានប្រពន្ធនាក់ ម្នាក់ឈ្មោះហាណា និងម្នាក់ទៀតឈ្មោះពេនីណា។
ពេនីណា មានកូនជាច្រើន ប៉ុន្តែ ហាណាវិញគ្មានកូនសូម្បីតែម្នាក់។ ដូច្នេះ ពេនីណាតែងតែមើលងាយហាណា។
ប៉ុន្តែ អែលកាណា គាត់ស្រឡាញ់ហាណាខ្លាំងជាង។ ពេនីណាបានដឹងរឿងនេះ ដូច្នេះពេលជួបហាណាម្តងៗ នាងតែងនិយាយបញ្ឈឺ ធ្វើឱ្យហាណាខឹង។
ដោយព្រោះ ហាណានាងគ្មានកូនដូចគេ ធ្វើឱ្យនាងឈឺចិត្តចង់បែកទ្រូង។ ពេលហាណាទៅព្រះវិហារនាងតែងតែយំនៅចំពោះព្រះជាម្ចាស់។
នាងបានអធិស្ឋានទៅព្រះជាម្ចាស់។ ហាណាបានប្រើពេលអស់ជាច្រើន អធិស្ឋានទៅព្រះជាម្ចាស់។
ពេលនោះ បូជាចារ្យអេលីបានចូលមកក្នុងព្រះវិហារ។ ហាណាបានអង្គុយអធិស្ឋានអស់ពេលយ៉ាងយូរ ដោយសម្លេងខ្សឹបៗ ឃើញតែបបូរមាត់កម្រើកតិចៗ ឃើញដូច្នេះ បូជាចារ្យអេលីគាត់គិតថានាងស្រវឹង ក៏ស្តីឱ្យនាង។
ហាណាក៏បាននិយាយទៅបូជាចារ្យថា៖ «ទេ លោកម្ចាស់ នាងខ្ញុំមិនបានស្រវឹងស្រាទេ។ នាងខ្ញុំកំពុងអធិស្ឋានទូលព្រះជាម្ចាស់អំពីទុក្ខព្រួយនិងរឿងអយុត្តិធម៌របស់នាងខ្ញុំទេ» ក្រោយបានស្តាប់រឿងរបស់ហាណាហើយ បូជាចារ្យអេលីបានប្រទានពរដល់ហាណា
ហាណាបានអរគុណហើយក៏ចាកចេញទៅ។ បន្ទាប់ពីនោះនាងក៏លែងខ្វល់ខ្វាយអ្វីទៀត ខំញ៉ាំ ខំគេង។ ទីបំផុត ព្រះជាម្ចាស់ក៏បាននឹកចាំពីហាណា។
ពេលហាណាត្រឡប់មកផ្ទះវិញ នាងក៏មានកូន។ ពេលសម្រាលមកដល់នាងក៏បង្កើតកូនប្រុសម្នាក់ ដាក់ឈ្មោះឱ្យថា សាំយូអែល។
ហាណាបានចិញ្ចឹមបីបាច់ផ្តល់ក្តីស្រឡាញ់ដល់សាំយូអែលរហូតដល់សាំយូអែលលែងបៅ។
ពេលសាំយូអែលលែងបៅ នាងក៏បានយកសាំយូអែលទៅព្រះវិហារតាមការសន្យារបស់នាងជាមួយព្រះជាម្ចាស់។
កុមារសាំយូអែលបានរស់នៅជាមួយបូជាចារ្យអេលី បម្រើព្រះជាម្ចាស់នៅក្នុងព្រះវិហារ។
ពីមួយថ្ងៃទៅមួយថ្ងៃ សាំយូអែលកាន់តែធំ គាត់កាន់តែចូលចិត្តនៅជាមួយព្រះជាម្ចាស់។
ទោះបីសាំយូអែលបានក្លាយជាមនុស្សពេញវ័យក៏ដោយ ព្រះជាម្ចាស់នៅតែគង់នៅជាមួយគាត់។
ដូច្នេះ មនុស្សទាំងអស់ បានដឹងថាសាំយូអែលនឹងក្លាយជាព្យាការីថ្មីក្នុងស្រុកអ៊ីស្រាអែល។
ក្រោយមក សាំយូអែលក៏បានគ្រប់គ្រងរាស្ត្រអ៊ីស្រាអែលជាមួយព្រះជាម្ចាស់ដោយជំនឿ និងបានចាក់ប្រេងតាំងឱ្យ ស្តេចអ៊ីស្រាអែលជាច្រើន។
ហើយគាត់ក៏បានក្លាយជាមនុស្សដ៏អស្ចារ្យដែលបង្រៀននិងផ្សព្វផ្សាយព្រះបន្ទូលព្រះជាម្ចាស់ទៅរាស្ត្រអ៊ីស្រាអែល ទាំងអស់។







**សកម្មភាពទី១**

កាត់បន្ទប់សាំយូអែលដោយកន្ត្រៃ រួចផ្គុំបន្ទប់ឱ្យរួចរាល់ ហើយបិទរូបលោកសាំយូអែលនៅលើគ្រែ។

**សម្ភារៈ៖ កន្ត្រៃ កាវ**







———— បន្ទាត់សម្រាប់កាត់

-------- បន្ទាត់បត់

រូបភាពរួចរាល់



**សកម្មភាពទី២** សូមឆ្លើយសំណួរខាងក្រោម។

a. តើអ្នកណាដែលមិនអាចមានកូនបាន ហើយស្វាមីរបស់នាងមានឈ្មោះអ្វី?

-----------------------------------------------------------------

b. សូមអាន ១សាំយូអែល១៖១០-១២ រួចឆ្លើយសំណួរ។ តើហាណាបានធ្វើអ្វីខ្លះ ដើម្បីឱ្យមានកូន ហើយនាងបានដាក់ឈ្មោះកូននោះដូចម្ដេច?

-----------------------------------------------------------------

c. តើយើងអាចរៀនបានអ្វីខ្លះ តាមរយៈនាងហាណានៅក្នុងរឿងនេះ?

-----------------------------------------------------------------

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (១សាំយូអែល១៖១១)

> ប្រសិនបើព្រះអង្គប្រោសប្រទានឲ្យខ្ញុំម្ចាស់មានកូនប្រុសមួយ ខ្ញុំម្ចាស់នឹងយកកូននោះមកថ្វាយព្រះអង្គ ដើម្បីឲ្យនៅបម្រើព្រះអង្គអស់មួយជីវិត